multicultural communication

English
March 2003
[BHC-6220]

# ថ្នាំបង្កប់ក្រោមស្បែសំរាប់ការពារកំណើតទារក- ពត៌មានសំរាប់ស្ត្រី
# Contraceptive implants – information for women

## តើថ្នាំបង្កប់ក្រោមស្បែកសំរាប់បង្ការកំណើតទារកជាអ្វី?

ថ្នាំបង្កប់ក្រោមស្បែកសំរាប់បង្ការកំណើតទារកមានដំណើរការដូចគ្នាទៅនឹងថ្នាំគ្រាប់បង្ការកំណើតទារក ដែរ។ ថ្នាំនេះមានអ័រម៉ូនមួយក្នុងចំណោមអ័រម៉ូននៅក្នុងថ្នាំគ្រាប់បង្ការកំណើតទារក។ អ័រម៉ូននេះ ការពារ មិនឲ្យមានគភ៌។ យ៉ាងណាមិញ ថ្នាំបង្កប់ក្រោមស្បែកសំរាប់បង្ការកំណើតទារកនេះ មិនមានរូបរាងជា គ្រាប់ទេ តែជាអ័រម៉ូន នៅក្នុងកូនបំពង់តូចស្តើងទន់មួយ។ កូនបំពង់នេះមានប្រវែង៤សង្ទីម៉ែត្រធ្វើ អំពីប្លាស្ទីក។ គេស៊កបង្កប់ថ្នាំនេះឲ្យនៅក្រោមស្បែក នៅខាងក្នុងដៃរបស់ស្ត្រី។ កិច្ចការនេះ ត្រូវតែ អនុវត្តឡើងដោយ វេជ្ជបណ្ឌិតម្នាក់ដែលមានការយល់ដឹងពីបច្ចេកទេសដាក់បង្កប់ថ្នាំនេះ។

ថ្នាំបង្កប់ក្រោមស្បែកសំរាប់បង្ការកំណើតទារកបញ្ចេញនូវជាតិអ័រម៉ូនបន្តិចម្តងៗជាទៀងទាត់។ ថ្នាំនេះ ការពាររាំងរាការមានភគ៌រយៈពេល៣ឆ្នាំ។ ថ្នាំបង្កប់ក្រោមស្បែកសំរាប់បង្ការកំណើតទារកនេះ ត្រូវតែយក ចេញនៅគ្រាបញ្ចប់ពេល៣ឆ្នាំ។ យ៉ាងណាមិញ ថ្នាំនេះ អាចដកចេញបាននៅពេលណាក៏បានដែរ ដោយវេជ្ជបណ្ឌិតដែលមានការយល់ដឹងអំពីរបៀបដកចេញ។

## តើថ្នាំបង្កប់ក្រោមស្បែកសំរាប់ការពារកំណើតទារកនេះ មានដំណើរការយ៉ាងណា?

ថ្នាំនេះការពាររាំងរាការមានគភ៌ដោយ

- បញ្ឈប់មិនឲ្យអណ្ឌាស័យ(អូវ៉ែរ)របស់ស្ត្រី បង្កើតពងជារៀងរាល់ខែ។
- ពង្រឹងភ្នាសដែលមាននៅក្នុងមាត់ស្បូនស្ត្រី(ច្រកចូលទៅក្នុងស្បូន)។ ដំណើរការនេះ ខាឃាំងមិនឲ្យមេជីវិតបុរសជ្រៀតចូលទៅក្នុង ដើម្បីជួបប្រសព្វជាមួយនឹងពងស្ត្រីបាន។

## តើថ្នាំនេះមានប្រសិទ្ធភាពប៉ុណ្ណាដែរ?

ថ្នាំបង្កប់ក្រោមស្បែកសំរាប់ការពារកំណើតទារកនេះ មានប្រសិទ្ធភាពជាង៩៩% ក្នុងកិច្ចការពារ ការមានភគ៌។ យ៉ាងណាមិញ សូមចងចាំថា គ្មានថ្នាំបង្ការកំណើតទារក ណាមួយមានប្រសិទ្ធភាព គួរទុកចិត្តបាន១០០%នោះទេ។

តើថ្នាំបង្កប់ក្រោមស្បែកសំរាប់ការពារកំណើតទារកនេះមានគុណសម្បត្តិអ្វីខ្លះ?

- បង្ការកំណើតទារកយ៉ាងមានប្រសិទ្ធភាពសំរាប់រយៈពេល៣ឆ្នាំ
- អ្នកមិនចាំបាច់រំលឹកចងចាំក្នុងការប្រើថ្នាំនេះជារៀងរាល់ថ្ងៃនោះទេ។
- មិនរំខានប៉ះពាល់ដល់ការរួមដំណេកឡើយ
- ថោក

## តើថ្នាំបង្កប់ក្រោមស្បែកបង្ការកំណើតទារកនេះមានគុណវិបត្តិអ្វីខ្លះ?

- ស្ត្រីដែលប្រើថ្នាំបង្កប់ក្រោមស្បែកនេះ មានការផ្លាស់ប្តូរខ្លះទៅនឹងការធ្លាក់ឈាមរដូវរបស់គេ។ ស្ត្រីភាគច្រើនធ្លាក់ឈាមតិចជាងពេលមុនប្រើថ្នាំនេះ ប៉ុន្តែស្ត្រីខ្លះ មានរដូវញឹកញាប់ជាងមុន ឬក៏យូរជាងមុន។
- ស្ត្រីខ្លះជួបនឹងការធ្វើទុក្ខបុកម្នេញនៃថ្នាំ អាចមានរួមទាំងការឈឺក្បាលនិងមុនមុខ។
- ថ្នាំនេះមិនការពារប្រឆាំងនឹងការឆ្លងកាមរោគ ជម្ងឺអេដស៍ ឬក៏ជម្ងឺថ្លើមជំពូក B ឡើយ។

## ចុះចំណែកភាពអាចមានកូនវិញ?

ថ្នាំបង្កប់ក្នុងស្បែកសំរាប់ការពារកំណើតទារកនេះ មិនជ្រៀតជ្រែតរំខានដល់ភាពអាចមាន កូនបានឡើយ នៅគ្រាដែលគេដកយកថ្នាំនេះចេញពីក្នុងស្បែកនោះ ហើយការធ្លាក់ឈាមរដូវ តាមធម្មតា គឺវិលត្រឡប់មកភាពប្រក្រតីឡើងវិញ នៅក្នុងរវាងពេលមួយខែ។

## តើអ្នកអាចមើលឃើញឬក៏ស្ទាបដឹងថ្នាំបង្កប់ក្នុងស្បែកនេះឬទេ?

អ្នកមិនអាចមើលឃើញថ្នាំនេះទេ ពីព្រោះគេបង្កប់វានៅក្រោមស្បែករបស់អ្នក។ ប៉ុន្តែអ្នកអាចស្ទាបដឹង ដោយការប៉ះស្ទាបកន្លែងបង្កប់ថ្នាំនោះ នៅក្នុងដៃ។

## តើអ្នកណាប្រហែលជាអាចជ្រើសរើសប្រើថ្នាំបង្កប់ក្រោមស្បែកនេះ?

ស្ត្រីណាមួយដែល

- ចង់បានការទប់បង្ការកំណើតទារកដ៏មានប្រសិទ្ធភាព រយៈពេលយូរហើយអាចផ្លាស់ប្តូរបាន។
- មានបំណងទទួលយកការផ្លាស់ប្តូរនៃរង្វង់ពេលនៃការធ្លាក់រដូវ។

ថ្នាំបង្កប់ក្រោមស្បែកនេះជាពិសេសអាចសមប្រកបចំពោះអ្នក បើសិនជាអ្នក

- មានបញ្ហាពិបាកចាំ ក្នុងការលេបថ្នាំគ្រាប់បង្ការកំណើតទារក។
- មិនចូលចិត្តវិធីបង្ការកំណើតទារកដទៃទៀត ឬក៏យល់ថាវិធីទាំងនោះមិនអាចជឿទុកចិត្តបាន។
- មិនអាចទទួលយកអ័រម៉ូនអ៊ីស្ត្រូនជិន (oestrogen)បាន។

ថ្នាំបង្កប់ក្រោមស្បែកសំរាប់បង្ការកំណើតទារកនេះ គឺជាវិធីមួយក្នុងចំណោមវិធីបង្ការកំណើតទារកផ្សេងៗទៀតជាច្រើន។ សូមពិភាក្សាជាមួយនឹងវេជ្ជបណ្ឌិតអ្នក អំពីជំរើសដែលមាន និងជំរើសដែលសមប្រកបបំផុតសំរាប់រូបអ្នក។

## តើអ្នកណាខ្លះដែលប្រហែលជាមិនអាចប្រើថ្នាំបង្កប់ក្រោមស្បែកនេះបាន?

ថ្នាំនេះប្រហែលជាមិនសមប្រកបចំពោះរូបអ្នកឡើយ បើសិនជាអ្នក៖

- មានជម្ងឺថ្លើមធ្ងន់ធ្ងរ
- ធ្លាក់ឈាមតាមទ្វារមាសមិនធម្មតា
- ប្រើថ្នាំពេទ្យដែលធ្វើឲ្យថ្នាំបង្កប់ក្រោមស្បែកនេះ មិនសូវមានប្រសិទ្ធភាព
- មានឈាមកក
- មិនអាចទទួលយកអ័រម៉ូនប្រូជេស្តេរ៉ូន (progesterone)បាន

## តើគេដាក់និងដកថ្នាំបង្កប់ក្រោមស្បែកនេះដោយវិធីណា?

គេដាក់ថ្នាំបង្កប់ក្រោមស្បែកនេះ ដោយប្រើថ្នាំស្ពឹកនៅជុំវិញកន្លែងដែលត្រូវដាក់។ ដំណើរការនេះ ត្រូវការពេលប្រហែលជាមួយនាទី។ ការដកយកថ្នាំបង្កប់ក្រោមស្បែកនេះ ក៏ធ្វើឡើងដោយការប្រើថ្នាំស្ពឹក ដូចគ្នាដែរ ដោយមានការកាត់វះបន្តិច។ ដំណើរការនេះ អាចធ្វើឲ្យមានស្លាមយ៉ាងតូចមួយ។ ការដាក់និងដក យកថ្នាំបង្កប់ក្រោមស្បែកនេះ ត្រូវតែធ្វើឡើងដោយវេជ្ជបណ្ឌិតម្នាក់ដែលមានការយល់ដឹងអំពីបច្ចេកទេស ដាក់និងដកនេះ។ ក្រោយពីការដាក់រួចនោះ អ្នកអាចស្ទាបដឹងបាន ប៉ុន្តែមិនគួរមើលឃើញថ្នាំនោះឡើយ។ បើសិនជាអ្នកមិនអាចស្ទាបដឹងថ្នាំនេះទេ សូមអញ្ជើញទៅជួបវេជ្ជបណ្ឌិតអ្នក។ សូមប្រើវិធីការពារកំណើត ទារកណាមួយផ្សេងទៀត ទម្រាំវេជ្ជបណ្ឌិតអាចប្រាប់អ្នកបានថា ថ្នាំនោះឋិតនៅនឹងកន្លែងដែលដាក់នោះនៅ ឡើយ។

## តើថ្នាំបង្កប់ក្រោមស្បែកនោះធ្វើឲ្យឈឺទេ?

ការប្រើថ្នាំបង្កប់ក្រោមស្បែកនេះ គឺមិនឈឺទេ។ ថ្នាំនេះអាចធ្វើឲ្យមានការជាំស្បែកខ្លះៗ និងធ្វើឲ្យឈឺ អួលៗបន្តិចបន្តួច ក្រោយពីដាក់រួច ឬក៏ដកយកចេញរួច។ ការឈឺអួលបន្តិចបន្តួចនេះ អាចមានរយៈពេល ដល់ទៅមួយអាទិត្យ។ ការប្រើបង់ស្អិតបិទពីលើដៃរយៈ ២៤ម៉ោង អាចជួយកាត់បន្ថយការជាំស្បែកនិងការ ឈឺអួលបន្តិចបន្តួចនេះ។ កន្លែងដែលដាក់ថ្នាំបង្កប់នេះ អាចរមាស់បន្តិចបន្តួច ប្រហែលជាពេល២ទៅ៣ថ្ងៃ។ ការចៀសវាងកុំញីត្រដុសស្បែកនៅម្តុំកន្លែងបង្កប់ថ្នាំ គឺជារឿងសំខាន់។

## តើខ្ញុំស្វែងរកវេជ្ជបណ្ឌិតដោយវិធីណា ដើម្បីធ្វើការពិភាក្សាអំពីរឿងដាក់ថ្នាំបង្កប់ក្រោមស្បែក សំរាប់បង្ការកំណើតទារកនេះ?

សូមទាក់ទងបណ្តាញទូរស័ព្ទសុខភាព FPA លេខ 1300 658 886។ មជ្ឈមណ្ឌលសុខភាព FPA មាន វេជ្ជបណ្ឌិតដែលអាចដាក់ថ្នាំបង្កប់ក្រោមស្បែកនេះបាន។ បណ្តាញទូរស័ព្ទសុខភាព FPA អាចណែនាំអ្នក ឲ្យទៅមជ្ឈមណ្ឌលជិតអ្នកបំផុត ឬក៏វេជ្ជបណ្ឌិតមួយផ្សេងទៀត ដែលមានការហ្វឹកហាត់ អំពីរបៀបដាក់ ថ្នាំបង្កប់ក្រោមស្បែកនេះ។ ឬក៏ទូរស័ព្ទទៅកិច្ចបំរើសុខភាពពហុវប្បធម៌ FPA (FPA Multicultural Health Services) តាមរយៈលេខ 02 9754 1322 ។

បើសិនជាអ្នកត្រូវការជំនួយដើម្បីនិយាយទូរស័ព្ទជាភាសាអង់គ្លេស សូមទាក់ទងកិច្ចបំរើបកប្រែភាសា (TIS) តាមរយៈលេខ 131 450 ។

អ្នកអាចរកពត៌មានជាភាសារបស់អ្នក នៅក្នុងអ៊ិនធឺណិតរបស់កិច្ចបំរើផ្តល់ពត៌មាន ពហុវប្បធម៌ (Multicultural Communication website): http://mhcs.health.nsw.gov.au.

លេខទូរស័ព្ទទាំងនេះ គឺជាលេខត្រឹមត្រូវ នៅគ្រាដែលបោះពុម្ពផ្សាយ ប៉ុន្តែមិនបានទទួលការកែតម្រូវ ជាហូរហែ។ លោកអ្នកប្រហែលជាត្រូវតែឆែករកលេខទូរស័ព្ទទាំងនោះ នៅក្នុងសៀវទូរស័ព្ទហើយ៕